ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ : ៤៧៣១ ប្រក

# ប្រកាស
## ស្តីពី
## បែបបទ និងនីតិវិធី
## នៃការស្នើសុំចុះបញ្ជី ការផ្តល់ ការកែតម្រូវទិន្នន័យ ការលុបបញ្ជី ការធ្វើមោឃភាព និងការដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ព្រមទាំងបណ្តឹងមិនសុខចិត្ត

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩ ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៤៧ អនក្រ.បក ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០២៥ ស្តីពីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- យោងតាមសំណើរបស់អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ កំណត់អំពីបែបបទ និងនីតិវិធី នៃការស្នើសុំចុះបញ្ជី ការផ្ដល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង ការផ្ដល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា ការកែតម្រូវទិន្នន័យ ការលុបបញ្ជី ការធ្វើមោឃភាព និងការដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ព្រមទាំងបែបបទ និងនីតិវិធីនៃការប្ដឹងមិនសុខចិត្ត ក្នុងគោលបំណងដើម្បីធានាដល់ការអនុវត្តសិទ្ធិកាតព្វកិច្ច និងផលប្រយោជន៍នានារបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដែលបានកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះរាល់ការងារពាក់ព័ន្ធនឹងការចុះបញ្ជី ការផ្ដល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង ការផ្ដល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា ការកែតម្រូវទិន្នន័យ ការលុបបញ្ជី ការធ្វើមោឃភាព និងការដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ព្រមទាំងបែបបទ និងនីតិវិធីនៃការប្ដឹងមិនសុខចិត្ត។

**ប្រការ៣.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យ ដូចខាងក្រោម៖

- **ការផ្ដល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង** សំដៅដល់ការផ្ដល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរលើកទី១ សម្រាប់បុគ្គលម្នាក់ៗ។
- **អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា** សំដៅដល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលផ្ដល់ថ្មីឡើងវិញ ក្នុងករណីអត្តសញ្ញាណបណ្ណនោះអស់សុពលភាព បាត់បង់ ខូចខាត ឬកែតម្រូវទិន្នន័យ។
- **ការកែតម្រូវទិន្នន័យ** សំដៅដល់ការកែតម្រូវទិន្នន័យអត្តសញ្ញាណបុគ្គលក្នុងបញ្ជី និងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដែលមានកំហុសទិន្នន័យឱ្យបានត្រឹមត្រូវ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តកំណត់។ ការកែតម្រូវទិន្នន័យ គឺជាទម្រង់នៃការផ្ដល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា ដែលអនុវត្តតាមនីតិវិធីដោយឡែក។
- **បណ្ដឹងឧបាស្រ័យ** សំដៅដល់ការប្ដឹងមិនសុខចិត្តទៅតាមឋានានុក្រម នៃកិច្ចការរដ្ឋបាល ពាក់ព័ន្ធការចាត់ចែង រួមទាំងសេចក្ដីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់អាជ្ញាធរមានសមត្ថកិច្ច។
- **ចុះនិទ្ទេស** សំដៅដល់ការកត់ត្រាដោយសង្ខេបនៅលើបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ក្នុងករណីសុំផ្ដល់ទុតិយតា ការកែតម្រូវទិន្នន័យ ការលុបបញ្ជី ការធ្វើមោឃភាព និងការដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។
- **ជនវិបល្លាសស្មារតី** សំដៅដល់ជនទាំងឡាយណាដែលមានបញ្ហាផ្នែកប្រព័ន្ធប្រសាទ វិកលចរិត សតិមិនប្រក្រតី ដែលមិនអាចយល់ដឹងនូវរាល់ទង្វើរបស់ខ្លួនបាន ដូចមនុស្សធម្មតា ក្នុងរយៈពេលមិនអាចកំណត់ ឬក្នុងរយៈពេលខ្លី។
- **ជននៅក្រោមហិតូបត្ថម្ភ** សំដៅដល់ជនដែលមានសមត្ថភាពតិចតួចក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ហើយត្រូវបានតុលាការដាក់ឱ្យស្ថិតនៅក្រោមការថែទាំដោយហិតូបត្ថម្ភកៈ។

## ជំពូកទី២
## បទប្បញ្ញត្តិរួម
### ផ្នែកទី១
### គោលការណ៍ទូទៅ

**ប្រការ៤.-**

ការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ រួមមាន៖

- ការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- ការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង
- ការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា
- ការកែតម្រូវទិន្នន័យអត្តសញ្ញាណបុគ្គលក្នុងបញ្ជី និងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- ការលុបបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- ការធ្វើមោឃភាពអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- ការដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និង
- ចំណាត់ការលើបណ្តឹងមិនសុខចិត្ត។

**ប្រការ៥.-**

អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវបានប្រើប្រាស់ក្នុងការកំណត់អត្តសញ្ញាណបុគ្គល ដែលមានសញ្ជាតិខ្មែរ ដើម្បីធានាការចូលរួមអនុវត្តសិទ្ធិ និងកាតព្វកិច្ចជាប្រជាពលរដ្ឋខ្មែរស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

ប្រជាពលរដ្ឋខ្មែរអាចប្រើប្រាស់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរក្នុងគោលបំណងផ្សេងៗ ដូចជា ការចុះឈ្មោះចូលរៀន ការបំពេញបែបបទចូលបម្រើការងារ ការចុះបញ្ជីអចលនវត្ថុ ការចុះបញ្ជីយានយន្ត ការបើកគណនីធនាគារ ការចុះបញ្ជីពាណិជ្ជកម្ម ការចុះកិច្ចសន្យា ឬការប្រើប្រាស់សេវារដ្ឋបាលផ្សេងទៀត លើកលែងតែមានបញ្ញត្តិដោយឡែក។

### ផ្នែកទី២
### សមត្ថកិច្ច

**ប្រការ៦.-**

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ជាសេនាធិការជូនក្រសួងមហាផ្ទៃ មានសមត្ថកិច្ចក្នុងការដឹកនាំគ្រប់គ្រង លើការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដូចមានកំណត់ក្នុងប្រការ៤ នៃប្រកាសនេះ។

នាយកដ្ឋានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ជាសេនាធិការជូនអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម មានសមត្ថកិច្ចក្នុងការបំពេញការងារ ដូចមានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើ។

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អាចបង្កើតក្រុមការងារចល័ត ដើម្បីចុះបញ្ជី និងផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ យោងតាមការចាំបាច់។

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អាចទទួល និងសម្រេចលើពាក្យបណ្តឹង ក្នុងករណីបាត់បង់ ឬខូចខាតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងសុំផ្តល់ថ្មីឡើងវិញតាមការស្នើសុំរបស់ប្រជាពលរដ្ឋ។

**ប្រការ៧.-**

ស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត អធិការនៃអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ មានភារកិច្ចទទួលខុសត្រូវដឹកនាំចាត់តាំងអនុវត្តការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងជាអ្នកចុះហត្ថលេខាលើបញ្ជីរាយនាមប្រជាពលរដ្ឋ ដែលស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង ស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា និងស្នើសុំកែតម្រូវទិន្នន័យ។

**ផ្នែកទី៣**

**មន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងដំណើរការការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ**

**ប្រការ៨.-**

មន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ រួមមាន៖

- មន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ នៃប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់
- មន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ នៃអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- មន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ នៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
- មន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ នៃស្នាក់ការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- មន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ នៃនាយកដ្ឋានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និង
- មន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ នៃកន្លែងផ្សេងទៀតតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**ប្រការ៩.-**

មន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ មានតួនាទីភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ កត់ត្រា និងចុះបញ្ជី ឬលើកចោលពាក្យសុំចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ តាមការកំណត់របស់ក្រសួងមហាផ្ទៃ
- រៀបចំបញ្ជីរាយនាមប្រជាពលរដ្ឋដែលបានបំពេញបែបបទរួចរាល់ ព្រមទាំងទិន្នន័យ ក្នុងការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង ការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា ការកែតម្រូវទិន្នន័យ បញ្ជូនទៅតាមឋានានុក្រមនៃកិច្ចការរដ្ឋបាលផ្នែកអត្តសញ្ញាណបណ្ណ មកអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដើម្បីពិនិត្យ សម្រេច និងបោះពុម្ព
- រៀបចំបែបបទទាក់ទងនឹងការលុបបញ្ជី ការធ្វើមោឃភាព និងការដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ បញ្ជូនទៅតាមឋានានុក្រមនៃកិច្ចការរដ្ឋបាល មកអគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដើម្បីពិនិត្យ និងសម្រេច
- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធលើការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- ផ្សព្វផ្សាយ និងរំលឹកដាស់តឿនដល់ប្រជាពលរដ្ឋអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនចំពោះការចុះបញ្ជី និងការប្រើប្រាស់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- ផ្តល់របាយការណ៍ពាក់ព័ន្ធការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ តាមឋានានុក្រមឱ្យបានទាន់ពេលវេលា និងត្រឹមត្រូវទៅតាមការកំណត់
- បំពេញភារកិច្ចចាំបាច់ផ្សេងទៀត តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**ប្រការ១០.-**

បុគ្គលដែលមានសញ្ជាតិខ្មែរគ្រប់រូប អាចស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង ស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា និងស្នើសុំកែតម្រូវទិន្នន័យក្នុងករណីមានកំហុសទិន្នន័យ នៅតាមទីកន្លែងដូចខាងក្រោម៖

- ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ នៃលំនៅឋានរបស់សាមីខ្លួនកំពុងរស់នៅ
- អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ នៃលំនៅឋានរបស់សាមីខ្លួនកំពុងរស់នៅ
- ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត នៃលំនៅឋានរបស់សាមីខ្លួនកំពុងរស់នៅ
- នាយកដ្ឋានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- ស្នាក់ការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- ទីតាំងចល័តនៃក្រុមការងារផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬ
- កន្លែងផ្សេងទៀតតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

បុគ្គលដែលទទួលបានព្រះរាជក្រឹត្យស្តីពីការចូលសញ្ជាតិខ្មែរ ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា និងស្នើសុំកែតម្រូវទិន្នន័យ ក្នុងករណីមានកំហុសទិន្នន័យ នៅនាយកដ្ឋានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ។

**ប្រការ១១.-**

ស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ដែលមានភារកិច្ចទទួលខុសត្រូវ ដូចមានកំណត់ក្នុងប្រការ៧ នៃប្រកាសនេះ ត្រូវបញ្ជូនទិន្នន័យ និងបញ្ជីរាយនាមប្រជាពលរដ្ឋ ដែលស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរមកកាន់នាយកដ្ឋានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ។

ក្នុងករណីចាំបាច់ ស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត អាចប្រគល់សិទ្ធិជូនស្នងការរងមួយរូប ដើម្បីពិនិត្យសម្រេច និងចុះហត្ថលេខាជំនួស។

ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត អាចបង្កើតក្រុមការងារចល័ត ដើម្បីចុះបញ្ជី និងផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវមានគណនេយ្យភាព លើការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ចំពោះមុខអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត។

**ប្រការ១២.-**

អធិការនៃអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ដែលមានភារកិច្ចទទួលខុសត្រូវ ដូចមានកំណត់ក្នុងប្រការ៧ នៃប្រកាសនេះ ត្រូវបញ្ជូនទិន្នន័យ និងបញ្ជីរាយនាមប្រជាពលរដ្ឋដែលស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ មកកាន់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត។

ក្នុងករណីចាំបាច់ អធិការនៃអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ អាចប្រគល់សិទ្ធិជូនអធិការរងមួយរូប ដើម្បីពិនិត្យសម្រេច និងចុះហត្ថលេខាជំនួស។

អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ អាចបង្កើតក្រុមការងារចល័ត ដើម្បីចុះបញ្ជី និងផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

អធិការនៃអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ត្រូវមានគណនេយ្យភាព លើការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ចំពោះមុខអភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

**ប្រការ១៣.–**

នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ដែលមានភារកិច្ចទទួលខុសត្រូវ ដូចមានកំណត់ក្នុងប្រការ៧ នៃប្រកាសនេះ ត្រូវបញ្ជូនទិន្នន័យ និងបញ្ជីរាយនាមប្រជាពលរដ្ឋដែលស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ មកកាន់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ។

ក្នុងករណីចាំបាច់ នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ អាចប្រគល់សិទ្ធិជូននាយរងប៉ុស្តិ៍មួយរូប ដើម្បីពិនិត្យ សម្រេច និងចុះហត្ថលេខាជំនួស។

ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ អាចបង្កើតក្រុមការងារចល័ត ដើម្បីចុះបញ្ជី និងផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ត្រូវមានគណនេយ្យភាព លើការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ចំពោះមុខមេឃុំ ចៅសង្កាត់។

## ជំពូកទី៣

## ការស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង ស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា និងស្នើសុំកែតម្រូវទិន្នន័យ

**ប្រការ១៤.–**

ប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលមានអាយុចាប់ពី ១៥(ដប់ប្រាំ)ឆ្នាំឡើង អាចស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង ស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា និងស្នើសុំកែតម្រូវទិន្នន័យ ក្នុងករណីមានកំហុសទិន្នន័យ។

ប្រជាពលរដ្ឋដែលស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង ស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា និងស្នើសុំកែតម្រូវទិន្នន័យ ត្រូវបង្ហាញខ្លួននៅចំពោះមុខមន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដើម្បីបំពេញបែបបទ ផ្តិតស្នាមខ្ទៅដៃ និងថតរូប។

អាណាព្យាបាលទូទៅរបស់ជនវិបល្លាសស្មារតី ឬជននៅក្រោមហិតូបត្ថម្ភ អាចមកស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង ស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា និងស្នើសុំកែតម្រូវទិន្នន័យ ក្នុងករណីមានកំហុសទិន្នន័យ ដោយនាំសាមីខ្លួនមកជាមួយ និងភ្ជាប់មកជាមួយនូវដីកាសម្រេចតុលាការទទួលស្គាល់ជាអ្នកអាណាព្យាបាល ឬលិខិតបញ្ជាក់ពីមន្ទីរពេទ្យ ឬលិខិតបញ្ជាក់ពីអាជ្ញាធរមូលដ្ឋានដែលសាមីខ្លួនកំពុងរស់នៅ។

**ប្រការ១៥.–**

សលាកបត្រស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ទាំងស្នើសុំផ្តល់ដំបូង ឬស្នើសុំផ្តល់ទុតិយតា ឬស្នើសុំកែតម្រូវទិន្នន័យ និងឧបសម្ព័ន្ធផ្សេងទៀតដែលកំណត់ក្នុងប្រកាសនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរតាមទម្រង់ជាក្រដាស ឬទម្រង់ជាអេឡិចត្រូនិក។

គំរូសលាកបត្រស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ សុំផ្តល់ដំបូង ឬសុំផ្តល់ទុតិយតា ករណីអស់សុពលភាព ឬបាត់បង់ ឬខូចខាត ឬកែតម្រូវទិន្នន័យ និងបង្កាន់ដៃទទួលអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ជាឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

## ជំពូកទី៤

## បែបបទ និងនីតិវិធីនៃការចុះបញ្ជី និងស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង និងការស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា

### ផ្នែកទី១

### ការចុះបញ្ជី និងស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង

**ប្រការ១៦.-**

ប្រជាពលរដ្ឋដែលស្នើសុំចុះបញ្ជី និងស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង ត្រូវបំពេញសលាកបត្រស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

ក- ចំពោះប្រជាពលរដ្ឋដែលមានដើមកំណើតជាខ្មែរ៖
- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត និង
- ឯកសារសម្គាល់ការស្នាក់នៅ (សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ មានបញ្ជាក់នីត្យានុកូលកម្ម ឬលិខិតបញ្ជាក់ទីលំនៅ)។

ខ- ចំពោះជនបរទេសដែលទទួលបានសញ្ជាតិខ្មែរ៖
- ព្រះរាជក្រឹត្យស្តីពីការចូលសញ្ជាតិខ្មែរ មានបញ្ជាក់នីត្យានុកូលកម្ម
- ឯកសារសម្គាល់ការស្នាក់នៅ (សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ មានបញ្ជាក់នីត្យានុកូលកម្ម ឬលិខិតបញ្ជាក់ទីលំនៅ) និង
- ច្បាប់ដើមលិខិតឆ្លងដែនសញ្ជាតិដើម ឬសេចក្តីចម្លងលិខិតឆ្លងដែនសញ្ជាតិដើម ដោយមានបញ្ជាក់នីត្យានុកូលកម្មពីស្ថាប័នមានសមត្ថកិច្ច។ ករណីបាត់លិខិតឆ្លងដែនសញ្ជាតិដើម ត្រូវភ្ជាប់ជាមួយឯកសារអត្តសញ្ញាណដើមផ្សេងទៀតដែលមានបិទរូបថត និងមានការបញ្ជាក់នីត្យានុកូលកម្មត្រឹមត្រូវស្របតាមនីតិវិធី។

គ- ចំពោះប្រជាពលរដ្ឋខ្មែរដែលកំពុងបំពេញជាបព្វជិតក្នុងព្រះពុទ្ធសាសនា ត្រូវភ្ជាប់ឯកសារបន្ថែមរួមមានឆាយា ឬសង្ឃដីកា ឬសុទ្ធិបត្រ។ ករណីលាចាកសិក្ខាបទ សាមីខ្លួនត្រូវស្នើសុំប្តូរទិន្នន័យនៅលើអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ រួមមានរូបថត និងអាសយដ្ឋាន។

ករណីមានការសង្ស័យអំពីសញ្ជាតិ មន្ត្រីមានសមត្ថកិច្ចអាចស្នើសុំឯកសារភស្តុតាងផ្លូវការបន្ថែម ដើម្បីបញ្ជាក់ថាសាមីជនជាពលរដ្ឋខ្មែរពិតប្រាកដ ឬទទួលបានសញ្ជាតិខ្មែរស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬអាចធ្វើការចុះពិនិត្យ និងស្រាវជ្រាវបន្ថែម។

**ប្រការ១៧.-**

បន្ទាប់ពីទទួលបានសលាកបត្រស្នើសុំ និងឯកសារភ្ជាប់ មន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរត្រូវធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់សលាកបត្រស្នើសុំ ជាមួយឯកសារភ្ជាប់ឱ្យបានត្រឹមត្រូវ ព្រមទាំងធ្វើការសម្ភាសដើម្បីកំណត់អត្តសញ្ញាណជាពលរដ្ឋខ្មែរ រួចឱ្យសាមីខ្លួនផ្តិតខ្មៅដៃនៅលើសលាកបត្រស្នើសុំ ពិនិត្យកិនភាគ ស្លាកស្នាម បន្ទាប់មកមន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវអនុវត្តការងារដូចខាងក្រោម៖

ក- ស្កេនឯកសារពាក់ព័ន្ធនានា។
ខ- ផ្តិតយកស្នាមខ្ចៅដៃជីវមាត្ររបស់អ្នកដាក់ពាក្យសុំ។
គ- ថតរូបឌីជីថល។
ឃ- ចុះហត្ថលេខាអេឡិចត្រូនិករបស់អ្នកដាក់ពាក្យសុំ។
ង- បញ្ចូលព័ត៌មាននៃសលាកបត្រស្នើសុំទៅក្នុងបញ្ជីដោយប្រព័ន្ធអេឡិចត្រូនិក។
ច- ចេញបង្កាន់ដៃទទួលអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ជូនអ្នកដាក់ពាក្យសុំ។

## ផ្នែកទី២
## ការស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា ករណីអស់សុពលភាព

**ប្រការ១៨.-**

ប្រជាពលរដ្ឋខ្មែរដែលប្រើប្រាស់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរអស់សុពលភាព ឬសុពលភាពនៅតិចជាង១៨០ (មួយរយប៉ែតសិប) ថ្ងៃ អាចដាក់ពាក្យស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតាបាន ដោយត្រូវបំពេញសលាកបត្រស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ អស់សុពលភាព និង
- ឯកសារសម្គាល់ការស្នាក់នៅ (សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ មានបញ្ជាក់នីត្យានុកូលកម្ម ឬលិខិតបញ្ជាក់ទីលំនៅ) ករណីផ្លាស់ប្តូរទីលំនៅ។

**ប្រការ១៩.-**

បន្ទាប់ពីទទួលបានសលាកបត្រស្នើសុំ និងឯកសារភ្ជាប់ មន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរត្រូវពិនិត្យ ផ្ទៀងផ្ទាត់សលាកបត្រស្នើសុំ ជាមួយឯកសារភ្ជាប់ឱ្យបានត្រឹមត្រូវ និងធ្វើការសម្ភាសដើម្បីកំណត់អត្តសញ្ញាណជាពលរដ្ឋខ្មែរ រួចឱ្យសាមីខ្លួនផ្តិតខ្ចៅដៃនៅលើពាក្យសុំផ្តល់ ពិនិត្យគិនភាគ ស្លាកស្នាម បន្ទាប់មកមន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរត្រូវអនុវត្តការងារដូចខាងក្រោម៖

ក- ស្កេនឯកសារពាក់ព័ន្ធនានា។
ខ- ផ្តិតយកស្នាមខ្ចៅដៃជីវមាត្ររបស់អ្នកដាក់ពាក្យសុំ។
គ- ថតរូបឌីជីថល។
ឃ- ចុះហត្ថលេខាអេឡិចត្រូនិក របស់អ្នកដាក់ពាក្យសុំ។
ង- បញ្ចូលព័ត៌មាននៃសលាកបត្រស្នើសុំទៅក្នុងបញ្ជីដោយប្រព័ន្ធអេឡិចត្រូនិក។
ច- ចេញបង្កាន់ដៃទទួលអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ជូនអ្នកដាក់ពាក្យសុំ។

## ផ្នែកទី៣
## ការស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា ករណីបាត់បង់ ឬខូចខាត

**ប្រការ២០.-**

ប្រជាពលរដ្ឋដែលមានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរបាត់បង់ ឬខូចខាត អាចដាក់ពាក្យស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតាបាន នៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ឬនៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដោយត្រូវបំពេញសលាកបត្រស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងភ្ជាប់ជាមួយពាក្យបណ្តឹងករណីបាត់បង់ ឬ ខូចខាត។

គំរូពាក្យបណ្ដឹងករណីបាត់បង់ ឬខូចខាតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ នៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ជាឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

គំរូពាក្យបណ្ដឹងករណីបាត់បង់ ឬខូចខាតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ នៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ជាឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ។

ចំពោះករណីខូចខាត ប្រជាពលរដ្ឋត្រូវភ្ជាប់បន្ថែមមកជាមួយអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដែលខូចខាតនោះ។

ប្រជាពលរដ្ឋដែលបានបាត់បង់ ឬខូចខាតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរជាញឹកញាប់ ចាប់ពីលើកទី៣ ឡើងទៅ ត្រូវមានការកិច្ចដាក់ឯកសារបញ្ជាក់មូលហេតុបន្ថែមជូនទៅមន្ត្រីមានសមត្ថកិច្ច ដើម្បីធ្វើការផ្ទៀងផ្ទាត់ និងស្រាវជ្រាវ។

**ប្រការ២១.-**

បន្ទាប់ពីទទួលបានសលាកបត្រស្នើសុំ និងឯកសារភ្ជាប់ មន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរត្រូវធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់សលាកបត្រស្នើសុំ ជាមួយឯកសារភ្ជាប់ឱ្យបានត្រឹមត្រូវ។ ករណីមន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរពិនិត្យឃើញមានភាពត្រឹមត្រូវហើយ ត្រូវចេញបង្កាន់ដៃទទួលអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ជូនអ្នកដាក់ពាក្យសុំ។

## ជំពូកទី៥
## បែបបទ និងនីតិវិធី នៃការស្នើសុំកែតម្រូវទិន្នន័យអត្តសញ្ញាណបុគ្គលក្នុងបញ្ជី និងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
### ផ្នែកទី១
### កំហុសទិន្នន័យដែលអាចកែតម្រូវ

**ប្រការ២២.-**

ករណីដែលអាចកែតម្រូវទិន្នន័យក្នុងបញ្ជី និងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ស្របតាម ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ត្រូវបានកំណត់ដូចខាងក្រោម៖

ក- កែតម្រូវទិន្នន័យក្នុងបញ្ជី និងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ តាមបញ្ជីអត្រានុកូលដ្ឋាន ដែលត្រូវបានកែតម្រូវរួច ស្របតាមបញ្ញត្តិនៃផ្នែកទី១០ (ការកែបញ្ជីអត្រានុកូលដ្ឋាន) នៃជំពូកទី២ (ការចុះបញ្ជីអត្រានុកូលដ្ឋាន)។

ខ- កែតម្រូវទិន្នន័យក្នុងបញ្ជី និងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ តាមបញ្ជីអត្រានុកូលដ្ឋាន ករណីបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរមានការកត់ត្រាខុសពីបញ្ជីអត្រានុកូលដ្ឋាន។

គ- ជនដែលទទួលបានសញ្ជាតិខ្មែរ ហើយមិនបានចុះបញ្ជីអត្រានុកូលដ្ឋាន អាចស្នើសុំកែតម្រូវទិន្នន័យអត្តសញ្ញាណរបស់ខ្លួននៅក្នុងបញ្ជី និងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដោយផ្អែកលើព័ត៌មានក្នុងព្រះរាជក្រឹត្យស្តីពីការចូលសញ្ជាតិរបស់ខ្លួន។

**ប្រការ២៣.-**

ក្នុងករណីដែលទិន្នន័យក្នុងបញ្ជីអត្រានុកូលដ្ឋានពុំមានកំហុស ប៉ុន្តែទិន្នន័យក្នុងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរមានកំហុសបច្ចេកទេស នោះការកែតម្រូវបានត្រូវកំណត់ដូចខាងក្រោម៖

ក- កំហុសបច្ចេកទេសដោយការវាយបញ្ចូលទិន្នន័យខុសចូលទៅក្នុងប្រព័ន្ធ ដូចជាកំហុសឆ្គងអក្ខរាវិរុទ្ធលើ៖

- គោត្តនាមនិង/ឬនាម (អក្សរខ្មែរ និង/ឬអក្សរឡាតាំង)
- ថ្ងៃខែឆ្នាំកំណើត
- ភេទ
- ទីកន្លែងកំណើត និង/ឬ
- អាសយដ្ឋាន។

ខ- កំហុសបច្ចេកទេសផ្សេងទៀត រួមទាំងការបំពេញបែបបទលើពាក្យស្នើសុំផ្តល់មានការភាន់ច្រឡំ ឬមិនច្បាស់លាស់ ឬខុសទៅនឹងឯកសារយោង ដែលបានភ្ជាប់មកជាមួយ សំដៅសម្រេចឱ្យបានបុគ្គលម្នាក់មានអត្តសញ្ញាណតែមួយ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ២៤.-**

ប្រជាពលរដ្ឋដែលបានផ្លាស់ប្តូរទីលំនៅ ហើយមានបំណងកែអាសយដ្ឋានលើសន្លឹកអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវភ្ជាប់មកជាមួយឯកសារដូចខាងក្រោម៖

- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរច្បាប់ដើម និង
- ឯកសារសម្គាល់ការស្នាក់នៅ (សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ មានបញ្ជាក់នីត្យានុកូលកម្ម ឬលិខិតបញ្ជាក់ទីលំនៅ) ។

## ផ្នែកទី២
## បែបបទ និងនីតិវិធីនៃការកែតម្រូវទិន្នន័យ

**ប្រការ២៥.-**

ប្រជាពលរដ្ឋដែលប្រើប្រាស់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ មានកំហុសទិន្នន័យ អាចដាក់ពាក្យស្នើសុំកែតម្រូវទិន្នន័យអត្តសញ្ញាណបុគ្គលក្នុងបញ្ជី និងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរបាន ដោយត្រូវបំពេញពាក្យស្នើសុំកែតម្រូវទិន្នន័យអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងសលាកបត្រស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដោយត្រូវភ្ជាប់ជាមួយនូវឯកសារដូចខាងក្រោម៖

ក- ករណីការកែតម្រូវទិន្នន័យ ដោយសារកំហុសបច្ចេកទេស

- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរច្បាប់ដើម
- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬព្រះរាជក្រឹត្យស្តីពីការចូលសញ្ជាតិខ្មែរ មានបញ្ជាក់នីត្យានុកូលកម្ម និង
- ឯកសារសម្គាល់ការស្នាក់នៅ (សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ មានបញ្ជាក់នីត្យានុកូលកម្ម ឬលិខិតបញ្ជាក់ទីលំនៅ)។

ខ- ករណីការកែតម្រូវទិន្នន័យ តាមការចែងកំណត់ក្នុងច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម

- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរច្បាប់ដើម
- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត និង/ឬសេចក្តីសម្រេចរបស់សាលារបស់តុលាការ និង/ឬសេចក្តីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋាន និង/ឬព្រះរាជក្រឹត្យស្តីពីការផ្តល់សញ្ជាតិខ្មែរ មានបញ្ជាក់នីត្យានុកូលកម្ម

- ឯកសារសម្គាល់ការស្នាក់នៅ (សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ មានបញ្ជាក់នីត្យានុកូលកម្ម ឬលិខិតបញ្ជាក់ទីលំនៅ)
- ឯកសារសម្អាងផ្សេងទៀត (ប្រសិនបើមាន)។

គំរូពាក្យស្នើសុំកែតម្រូវទិន្នន័យ អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ជាឧបសម្ព័ន្ធទី៤ នៃប្រកាសនេះ។

**ប្រការ២៦.-**

បន្ទាប់ពីទទួលបានពាក្យស្នើសុំកែតម្រូវទិន្នន័យ និងសលាកបត្រស្នើសុំ ព្រមទាំងឯកសារភ្ជាប់ មន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវពិនិត្យ ផ្ទៀងផ្ទាត់ពាក្យស្នើសុំកែតម្រូវទិន្នន័យ សលាកបត្រស្នើសុំជាមួយឯកសារភ្ជាប់ឱ្យបានត្រឹមត្រូវ។

ករណីពិនិត្យឃើញថា មានភាពត្រឹមត្រូវហើយ មន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវចេញបង្កាន់ដៃទទួលអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ជូនអ្នកដាក់ពាក្យសុំ។

## ផ្នែកទី៣
## ករណីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរអស់សុពលភាព និង/ឬបាត់បង់ និង/ឬខូចខាត និង/ឬកែតម្រូវទិន្នន័យ ក្នុងពេលដំណាលគ្នា

**ប្រការ២៧.-**

ប្រជាពលរដ្ឋដែលមានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរអស់សុពលភាព បាត់បង់ ខូចខាត និង/ឬត្រូវកែតម្រូវទិន្នន័យក្នុងពេលដំណាលគ្នា អាចស្នើសុំផ្តល់ឡើងវិញបានក្នុងពេលតែមួយ។

មន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវពិនិត្យ ផ្ទៀងផ្ទាត់ឯកសារភ្ជាប់ដូចមានកំណត់ក្នុងប្រការ១៨ ប្រការ២០ ប្រការ២៤ និងប្រការ២៥ នៃប្រកាសនេះ និងអនុវត្តតាមនីតិវិធីកំណត់។

## ជំពូកទី៦
## ការសម្រេចលើសំណើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

**ប្រការ២៨.-**

បន្ទាប់ពីទទួលបានទិន្នន័យ បញ្ជីរាយនាម និងសំណុំឯកសារពាក់ព័ន្ធផ្សេងៗ ដែលស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង ឬស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា ពីស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ឬស្នាក់ការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬកន្លែងផ្សេងទៀតតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នាយកដ្ឋានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរត្រូវពិនិត្យ និងលើកយោបល់ជូនអគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មដើម្បីពិនិត្យ និងសម្រេច។

បន្ទាប់ពីទទួលបានគោលការណ៍សម្រេចពីអគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នាយកដ្ឋានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវចុះនិទ្ទេសទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ រួចហើយធ្វើការបោះពុម្ពអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដើម្បីផ្តល់ជូនប្រជាពលរដ្ឋ។

ក្នុងករណីមានការសង្ស័យ ឬមានភាពមិនប្រក្រតី នាយកដ្ឋានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវសហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីស្រាវជ្រាវបន្ថែមឱ្យបានច្បាស់លាស់ រួចលើកយោបល់ជូនអគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ពិនិត្យ និងសម្រេច។

**ប្រការ២៩.-**

ក្នុងករណីបដិសេធសំណើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង ឬស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា មន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់អំពីការបដិសេធនោះជាលាយលក្ខណ៍អក្សរ ឱ្យទៅអ្នកដាក់ពាក្យសុំ។

គំរូលិខិតបដិសេធសំណើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង ឬស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា ជាឧបសម្ព័ន្ធទី៥ នៃប្រកាសនេះ។

## ជំពូកទី៧
## រយៈពេល នៃការចុះបញ្ជី ការផ្តល់ និងការប្រគល់ ទទួលអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

**ប្រការ៣០.-**

ការស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង និងស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា ករណីអស់សុពលភាព ឬបាត់បង់ ឬខូចខាត មានរយៈពេល ២១(ម្ភៃមួយ)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលប្រជាពលរដ្ឋបានដាក់ពាក្យស្នើសុំ។

ការស្នើសុំអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា ករណីកែតម្រូវទិន្នន័យ មានរយៈពេល ១៤ (ដប់បួន)ថ្ងៃ ទៅ ២១(ម្ភៃមួយ)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលប្រជាពលរដ្ឋបានដាក់ពាក្យស្នើសុំ អាស្រ័យទៅលើប្រភេទនៃកំហុសទិន្នន័យ។

រយៈពេលកែតម្រូវទិន្នន័យ ដូចមានកំណត់ក្នុងកថាខណ្ឌទី២ ខាងលើ អាចត្រូវបានពន្យារពេលក្នុងករណីចាំបាច់មួយចំនួន ដែលត្រូវការពេលវេលាសមស្របដើម្បីស្រាវជ្រាវ។

**ប្រការ៣១.-**

ការស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង និងស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា សម្រាប់សេវាឆាប់រហ័សដោយមានបង់កម្រៃសេវា ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**ប្រការ៣២.-**

រយៈពេលនៃការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា ត្រូវបានបែងចែកតាមឋានានុក្រម នៃកិច្ចការរដ្ឋបាល ដូចខាងក្រោម៖

- ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ឬទីកន្លែងដែលកំណត់ដោយក្រសួងមហាផ្ទៃ ត្រូវប្រមូលទិន្នន័យ គិតពីថ្ងៃដែលប្រជាពលរដ្ឋបានដាក់ពាក្យស្នើសុំចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា ពីប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ឬទីកន្លែងដែលកំណត់ដោយក្រសួងមហាផ្ទៃ ហើយបញ្ជូនឯកសារភ្ជាប់ បញ្ជីរាយនាមប្រជាពលរដ្ឋ បញ្ជីស្នើសុំចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា និងទិន្នន័យ មកអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ ក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ។

- អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ ត្រូវពិនិត្យសម្រេច បោះពុម្ព និងប្រគល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ជូនស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ឬទីកន្លែងដែលកំណត់ដោយក្រសួងមហាផ្ទៃ ក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ។
- ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ឬទីកន្លែងដែលកំណត់ដោយក្រសួងមហាផ្ទៃ ត្រូវមានភាពម្ចាស់ការក្នុងការបែងចែកអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរតាមឋានានុក្រមជូនដល់ដៃប្រជាពលរដ្ឋ ក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ។

**ប្រការ៣៣.-**

ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍មកអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដូចខាងក្រោម៖

- របាយការណ៍ស្ដីពីវឌ្ឍនភាពការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ រៀងរាល់ខែ និង
- របាយការណ៍ស្ដីពីការប្រគល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដល់ដៃប្រជាពលរដ្ឋ ក្នុងរយៈពេលមិនឱ្យលើសពី ១(មួយ)ខែ បន្ទាប់ពីប្រគល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋ។

## ជំពូកទី៨
## បែបបទ និងនីតិវិធី នៃការលុបបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ការធ្វើមោឃភាពអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងការដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
### ផ្នែកទី១
### សមត្ថកិច្ច និងលក្ខខណ្ឌ

**ប្រការ៣៤.-**

មន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវធ្វើការដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរជាបណ្ដោះអាសន្នក្នុងករណីពិនិត្យឃើញថាអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរណាមួយសង្ស័យ ឬមានភាពមិនប្រក្រតី ក្នុងលក្ខខណ្ឌលុបបញ្ជី និង/ឬមោឃភាព។

អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម មានសមត្ថកិច្ចក្នុងការពិនិត្យសម្រេច លើការលុបបញ្ជីមោឃភាព និងដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ តាមបែបបទ និងនីតិវិធីកំណត់។

**ប្រការ៣៥.-**

ការលុបបញ្ជី ត្រូវបានធ្វើឡើងក្នុងលក្ខខណ្ឌណាមួយដែលបានកំណត់ដូចខាងក្រោម៖

- ការចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ខុសពីនីតិវិធីកំណត់ដោយច្បាប់
- បុគ្គលដែលបានចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ បានទទួលមរណភាព
- បុគ្គលដែលបានចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ បានបាត់សញ្ជាតិខ្មែរ។

**ប្រការ៣៦.-**

អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរត្រូវបានធ្វើមោឃភាព ក្នុងករណីណាមួយដូចខាងក្រោម៖

- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលបានចេញខុសនីតិវិធីកំណត់ដោយច្បាប់ ឬដោយបំពាន
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលបានចេញដោយបុគ្គលដែលគ្មាននីតិសម្បទា
- បើរកឃើញថាបុគ្គលណាម្នាក់បាននិងកំពុងប្រើប្រាស់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដែលនៅមានសុពលភាព លើសពី១(មួយ)

- បើរកឃើញថាបុគ្គលដែលបានចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរបានទទួលមរណភាព
- បើរកឃើញថាបុគ្គលដែលបានចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរបានបាត់សញ្ជាតិខ្មែរ។

**ប្រការ៣៧.-**

អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវបានដកហូត ក្នុងករណីលុបចោល ឬមោឃភាព ដូចបានចែងក្នុងប្រការ៣៥ និងប្រការ៣៦ នៃប្រកាសនេះ។

បទប្បញ្ញត្តិដែលមានចែងក្នុងកថាខណ្ឌទី១ខាងលើ មិនរារាំងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងការចេញប្រកាសកំណត់នូវលក្ខខណ្ឌផ្សេងទៀតឡើយ។

## ផ្នែកទី២
## ការដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ក្នុងលក្ខខណ្ឌលុបបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងមោឃភាពអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

**ប្រការ៣៨.-**

ការដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរជាបណ្ដោះអាសន្ន មន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវរៀបចំសំណើ និងឯកសារពាក់ព័ន្ធ ទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដើម្បីពិនិត្យ និងសម្រេច ដោយភ្ជាប់មកជាមួយនូវ៖

- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលបានដកហូត
- កំណត់ហេតុដកហូត ដោយមានការចូលរួមពីមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធ និង
- ឯកសារពាក់ព័ន្ធផ្សេងៗទៀត។

**ប្រការ៣៩.-**

បន្ទាប់ពីទទួលបានសំណើដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរជាបណ្ដោះអាសន្ន នាយកដ្ឋានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវពិនិត្យ ស្រាវជ្រាវ និង/ឬសហការស្រាវជ្រាវជាមួយសមត្ថកិច្ចពាក់ព័ន្ធ រួចលើកយោបល់ជូនអគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដើម្បីពិនិត្យ និងសម្រេច។

**ប្រការ៤០.-**

ការសម្រេចដកហូត ក្នុងលក្ខខណ្ឌលុបបញ្ជី និង/ឬមោឃភាពអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវចេញជាសេចក្ដីសម្រេចស្ដីពីការដកហូតនោះ។

នាយកដ្ឋានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ត្រូវអនុវត្តតាមនីតិវិធីកំណត់ ដោយត្រូវចម្លងសេចក្ដីសម្រេចស្ដីពីការដកហូត ក្នុងលក្ខខណ្ឌលុបបញ្ជី និង/ឬមោឃភាពអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ជូនសមត្ថកិច្ចពាក់ព័ន្ធ ហើយត្រូវចុះនិទ្ទេសទៅក្នុងប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដោយបញ្ជាក់អំពីមូលហេតុនៃការលុបបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និង/ឬមោឃភាព និងដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនោះ រួចត្រូវវាយត្រា "មោឃៈ" លើអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងរក្សាទុកឯកសារពាក់ព័ន្ធនៅក្នុងប្រព័ន្ធ។

មន្ត្រីជំនាញនៃនាយកដ្ឋានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ មិនត្រូវលុបបំបាត់បញ្ជីនោះពីក្នុងប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរឡើយ។

## ជំពូកទី៩
## បែបបទ និងនីតិវិធីនៃការប្តឹងមិនសុខចិត្ត
## ផ្នែកទី១
## ការដាក់ពាក្យបណ្តឹងមិនសុខចិត្ត

**ប្រការ៤១.-**

បុគ្គលដែលមិនសុខចិត្តចំពោះការបដិសេធមិនចុះបញ្ជី ឬកែតម្រូវបញ្ជី ឬការធ្វើមោឃភាព ឬការលុបបញ្ជី ឬការដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬសំណើផ្សេងៗទៀត របស់មន្ត្រីចុះបញ្ជី ឬការចាត់ចែង ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែង ឬសេចក្តីសម្រេចរបស់មន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ មានសិទ្ធិដាក់ពាក្យបណ្តឹងឧបាស្រ័យបាន។

រាល់ការធ្វើបណ្តឹងមិនសុខចិត្ត ដែលបានចែងកំណត់ក្នុងកថាខណ្ឌទី១ ខាងលើ មិនរារាំងការប្តឹងទៅតុលាការដោយផ្ទាល់ឡើយ ទោះនៅដំណាក់កាលណាមួយក៏ដោយ។

គំរូពាក្យបណ្តឹងមិនសុខចិត្ត ជាឧបសម្ព័ន្ធទី៦ នៃប្រកាសនេះ។

## ផ្នែកទី២
## ទីកន្លែងដាក់ពាក្យបណ្តឹងមិនសុខចិត្ត

**ប្រការ៤២.-**

បុគ្គលដែលមិនសុខចិត្តនឹងមន្ត្រីចុះបញ្ជីចំពោះការចាត់ចែង ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែង រួមទាំងសេចក្តីសម្រេច អាចដាក់ពាក្យបណ្តឹងនៅទីកន្លែងចុះបញ្ជីដែលមានឋានានុក្រមខ្ពស់ជាងមួយថ្នាក់ ដូចខាងក្រោម៖

- ករណីបុគ្គលដែលមិនសុខចិត្តនឹងមន្ត្រីចុះបញ្ជីនៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ត្រូវដាក់ពាក្យបណ្តឹងនៅអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ករណីបុគ្គលដែលមិនសុខចិត្តនឹងមន្ត្រីចុះបញ្ជីនៅអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ត្រូវដាក់ពាក្យបណ្តឹងនៅស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
- ករណីបុគ្គលដែលមិនសុខចិត្តនឹងមន្ត្រីចុះបញ្ជីនៅស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ឬនាយកដ្ឋានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬទីកន្លែងដែលកំណត់ដោយក្រសួងមហាផ្ទៃ ត្រូវដាក់ពាក្យបណ្តឹងនៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ
- ករណីបុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវដាក់ពាក្យបណ្តឹងទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ផ្នែកទី៣
## ដំណើរការ នៃការដាក់ពាក្យបណ្តឹងមិនសុខចិត្ត

**ប្រការ៤៣.-**

ក្នុងករណីបុគ្គលដែលបានស្នើសុំទៅមន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដើម្បីស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង និងស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា ឬសំណើផ្សេងទៀត នៅប៉ុស្តិ៍នគរបាលរដ្ឋបាល ឃុំ សង្កាត់ ហើយបុគ្គលនោះកើតទុក្ខមិនសុខចិត្តនឹងការចាត់ចែង ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែង អាចដាក់ពាក្យបណ្តឹងទៅអធិការដ្ឋាននគរបាល ក្រុង ស្រុក ខណ្ឌ ដែលខ្លួនរស់នៅបាន។

បន្ទាប់ពីទទួលបានពាក្យបណ្តឹងមិនសុខចិត្តរបស់ប្រជាពលរដ្ឋ មន្ត្រីទទួលបន្ទុកដោះស្រាយពាក្យបណ្តឹងនៅអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការពិនិត្យអំពីភាពត្រឹមត្រូវនៃបណ្តឹង និងឯកសារភ្ជាប់ រួចធ្វើការដោះស្រាយក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ។

ក្នុងករណីអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ បដិសេធបណ្តឹងមិនសុខចិត្តរបស់ប្រជាពលរដ្ឋ អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ត្រូវចេញសេចក្តីសម្រេចស្តីពីការបដិសេធនោះ ដោយចុះមូលហេតុច្បាស់លាស់ រួចផ្ញើជូនសាមីខ្លួនក្នុងរយៈពេល ៣(បី)ថ្ងៃ នៃថ្ងៃធ្វើការ។

ក្នុងករណីអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ មិនបានឆ្លើយតប ឬបដិសេធបណ្តឹងមិនសុខចិត្តរបស់ប្រជាពលរដ្ឋ សាមីខ្លួនអាចធ្វើបណ្តឹងឧបាស្រ័យទៅស្នងការដ្ឋាននគរបាលរាជធានី ខេត្ត។

**ប្រការ៤៤.-**

ក្នុងករណីបុគ្គលដែលបានស្នើសុំទៅមន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដើម្បីស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា ឬសំណើផ្សេងទៀតនៅអធិការដ្ឋាននគរបាលរដ្ឋបាលក្រុង ស្រុក ខណ្ឌ ហើយបុគ្គលនោះកើតទុក្ខមិនសុខចិត្តនឹងការចាត់ចែង ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែង ឬមិនពេញចិត្តនឹងសេចក្តីសម្រេចបដិសេធរបស់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ អាចដាក់ពាក្យបណ្តឹងទៅស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ដែលខ្លួនរស់នៅបាន។

បន្ទាប់ពីទទួលបានពាក្យបណ្តឹងមិនសុខចិត្តរបស់ប្រជាពលរដ្ឋ មន្ត្រីទទួលដោះស្រាយពាក្យបណ្តឹងនៅស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវធ្វើការពិនិត្យអំពីភាពត្រឹមត្រូវនៃបណ្តឹង និងឯកសារភ្ជាប់ និង/ឬសេចក្តីសម្រេចបដិសេធរបស់មន្ត្រីថ្នាក់ក្រោម រួចធ្វើការដោះស្រាយ ក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ។

ក្នុងករណីស្នងការដ្ឋាននគរបាលរាជធានី ខេត្ត បដិសេធបណ្តឹងមិនសុខចិត្តរបស់ប្រជាពលរដ្ឋ ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវចេញសេចក្តីសម្រេចស្តីពីការបដិសេធនោះ ដោយចុះមូលហេតុច្បាស់លាស់ រួចផ្ញើជូនសាមីខ្លួនក្នុងរយៈពេល ៣(បី)ថ្ងៃ នៃថ្ងៃធ្វើការ។

ក្នុងករណីស្នងការដ្ឋាននគរបាលរាជធានី ខេត្ត មិនបានឆ្លើយតប ឬបដិសេធបណ្តឹងមិនសុខចិត្តរបស់ប្រជាពលរដ្ឋ សាមីខ្លួនអាចធ្វើបណ្តឹងឧបាស្រ័យទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មបាន។

**ប្រការ៤៥.-**

ក្នុងករណីបុគ្គលដែលបានស្នើសុំទៅមន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដើម្បីសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង ឬសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា ឬសំណើផ្សេងទៀតនៅស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ហើយបុគ្គលនោះកើតទុក្ខមិនសុខចិត្តនឹងការចាត់ចែង ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែង ឬមិនពេញចិត្តនឹងសេចក្តីសម្រេចបដិសេធរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត អាចដាក់ពាក្យបណ្តឹងទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មបាន។

បន្ទាប់ពីទទួលបានពាក្យបណ្តឹងមិនសុខចិត្តរបស់ប្រជាពលរដ្ឋ មន្ត្រីទទួលដោះស្រាយពាក្យបណ្តឹងនៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវធ្វើការពិនិត្យអំពីភាពត្រឹមត្រូវនៃបណ្តឹង និងឯកសារភ្ជាប់ និង/ឬសេចក្តីសម្រេចបដិសេធរបស់មន្ត្រីថ្នាក់ក្រោម រួចធ្វើការដោះស្រាយ ក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ។

បុគ្គលដែលបានដាក់ពាក្យបណ្តឹងមិនសុខចិត្ត ត្រូវទៅទទួលយកសេចក្តីសម្រេចរបស់អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រោយរយៈពេល ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃដាក់ពាក្យបណ្តឹងមិនសុខចិត្ត។

**ប្រការ៤៦.-**

បុគ្គលដែលបានស្នើសុំទៅមន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដើម្បីស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង និងស្នើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា ឬសំណើផ្សេងទៀត នៅនាយកដ្ឋានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬទីកន្លែងផ្សេងទៀតដែលកំណត់ដោយក្រសួងមហាផ្ទៃ ហើយបុគ្គលនោះកើតទុក្ខមិនសុខចិត្តនឹងការចាត់ចែង ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែង អាចដាក់ពាក្យបណ្តឹងទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។

បន្ទាប់ពីទទួលបានពាក្យបណ្តឹងមិនសុខចិត្តរបស់ប្រជាពលរដ្ឋ មន្ត្រីទទួលដោះស្រាយពាក្យបណ្តឹងនៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវធ្វើការពិនិត្យអំពីភាពត្រឹមត្រូវនៃបណ្តឹង និងឯកសារភ្ជាប់ និង/ឬសេចក្តីសម្រេចបដិសេធរបស់មន្ត្រីថ្នាក់ក្រោម រួចធ្វើការដោះស្រាយក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ។

បុគ្គលដែលបានដាក់ពាក្យបណ្តឹងមិនសុខចិត្ត ត្រូវទៅទទួលយកសេចក្តីសម្រេចរបស់អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៅនាយកដ្ឋានរដ្ឋបាលសរុប នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រោយរយៈពេល ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃដាក់ពាក្យបណ្តឹងមិនសុខចិត្ត។

**ប្រការ៤៧.-**

បុគ្គលដែលមិនពេញចិត្តចំពោះសេចក្តីសម្រេចរបស់អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម រួមទាំងសេចក្តីសម្រេចលុបបញ្ជី មោឃភាព ឬដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ អាចដាក់ពាក្យបណ្តឹងទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការសម្រេចលើបណ្តឹងមិនសុខចិត្ត ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃដែលបានទទួលបណ្តឹងមិនសុខចិត្ត។ ការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញជាសេចក្តីសម្រេច។

ក្នុងករណីបុគ្គលណាម្នាក់មិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បុគ្គលនោះអាចដាក់ពាក្យបណ្តឹងទៅតុលាការ ដែលមានសមត្ថកិច្ចក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេចនោះ។

## ផ្នែកទី៤
## ទណ្ឌកម្មរដ្ឋបាល

**ប្រការ៤៨.-**

ករណីរកឃើញកំហុសរបស់មន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ពាក់ព័ន្ធការចាត់ចែង ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែង រួមទាំងសេចក្តីសម្រេចរបស់មន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលមានកំហុស ត្រូវទទួលរងនូវទណ្ឌកម្មរដ្ឋបាលដូចខាងក្រោម៖

- ហៅមកណែនាំ និងធ្វើការកែតម្រូវកំហុស និង/ឬ
- អនុវត្តតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតស្តីពីការដាក់ទណ្ឌកម្មរដ្ឋបាល។

**ប្រការ៤៩.-**

បែបបទ និងនីតិវិធីនៃការដាក់ទណ្ឌកម្មចំពោះមន្ត្រីចុះបញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដែលបានប្រព្រឹត្តនូវកំហុសពាក់ព័ន្ធការចាត់ចែង ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែង រួមទាំងសេចក្តីសម្រេច ត្រូវអនុវត្តតាមលិខិតបទដ្ឋានរបស់ស្ថាប័ន ឬអង្គភាពបានកំណត់។

## ជំពូកទី១០
## អន្តរប្បញ្ញត្តិ

**ប្រការ៥០.-**

អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដែលចេញឱ្យប្រជាពលរដ្ឋ ធ្វើឡើងមុនពេលមានប្រកាសនេះ ហើយនៅមានសុពលភាព ត្រូវបន្តប្រើប្រាស់រហូតដល់អស់សុពលភាព។

ក្រោយពេលប្រកាសនេះត្រូវបានអនុវត្ត នីតិវិធីណាដែលបានចាប់ផ្តើមហើយដោយអនុលោមតាមលិខិតបទដ្ឋានចាស់តែមិនទាន់ចប់ ត្រូវបន្តនីតិវិធីដោយអនុលោមតាមលិខិតបទដ្ឋានចាស់។

## ជំពូកទី១១
## អវសានប្បញ្ញត្តិ

**ប្រការ៥១.-**

ប្រកាសលេខ៦៣៧៥ ប្រ.ក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីនីតិវិធី លក្ខខណ្ឌនៃការសុំការផ្តល់ការប្រើប្រាស់ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ប្រកាសលេខ២០៦៥ ប្រ.ក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលប្រការ៣ នៃប្រកាសលេខ៦៣៧៥ ប្រ.ក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីនីតិវិធីលក្ខខណ្ឌនៃការសុំ ការផ្តល់ ការប្រើប្រាស់ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥២.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានកសុ្ខភាពនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានអង្គភាពពាក់ព័ន្ធ និងរដ្ឋបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៤ កើត ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៥២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ..៤៧៣១ ប្រក...ចុះថ្ងៃទី..១១.....ខែ..មេសា...ឆ្នាំ២០២៤
ស្តីពីបែបបទ និងនីតិវិធី នៃការស្នើសុំចុះបញ្ជី ការផ្តល់ ការកែតម្រូវទិន្នន័យ ការលុបបញ្ជី ការធ្វើមោឃភាព
និងការដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ព្រមទាំងបណ្តឹងមិនសុខចិត្ត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**
**អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម**

## សលាកបត្រស្នើសុំផ្តល់
## អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

ទីកន្លែងផ្តល់ (ប៉ុស្តិ៍/អធិការដ្ឋាន/ស្នងការដ្ឋាន/
ស្នាក់ការ/ឬនាយកដ្ឋាន) ....................................

01001096876

☐ សុំផ្តល់ដំបូង ឬសុំផ្តល់ទុតិយតាករណី ☐ អស់សុពលភាព ☐ បាត់បង់ ☐ ខូចខាត ☐ កែតម្រូវទិន្នន័យ

នាមត្រកូល និងនាមខ្លួន..................................អក្សរឡាតាំង.................................. ជនជាតិ.........
ភេទ.........ថ្ងៃ ខែ ឆ្នាំកំណើត.........................លេខអត្តសញ្ញាណបណ្ណ.......................... សញ្ជាតិ.........
ទីកន្លែងកំណើត ភូមិ..........................................ឃុំ/សង្កាត់.................................. សាសនា.........
ក្រុង/ស្រុក/ខណ្ឌ..............................................រាជធានី/ខេត្ត..................................
អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ..............ផ្លូវ............ភូមិ.........................ឃុំ/សង្កាត់..............................
ក្រុង/ស្រុក/ខណ្ឌ...............................រាជធានី/ខេត្ត..............................ទូរស័ព្ទ..................................
មុខរបរ..............................................................................................................................

ឈ្មោះឪពុក.........................................អាយុ..............ឆ្នាំ ជនជាតិ.....................សញ្ជាតិ..................
ឈ្មោះម្តាយ.........................................អាយុ..............ឆ្នាំ ជនជាតិ.....................សញ្ជាតិ..................
អាសយដ្ឋានឪពុក ម្តាយ.........................................................................................................
ឈ្មោះប្តី ឬប្រពន្ធ..................................អាយុ..............ឆ្នាំ ជនជាតិ.....................សញ្ជាតិ..................
ទំនាក់ទំនងករណីមានអាសន្ន ឈ្មោះ................................................ទូរស័ព្ទ................................

រូបរាង កម្ពស់...................ស.ម សម្បុរ..........................
ស្លាកស្នាមពិសេស ......................................................
..........................................................................
ឈ្មោះធ្លាប់ហៅ................................................................
លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល
UIC: _ _ _ – _ _ _ – _ _ _ _

ថ្ងៃទី.........ខែ...........ឆ្នាំ២០.....
ស្នាមមេដៃទាំងពីរ

| មេដៃឆ្វេង | មេដៃស្តាំ |
|---|---|
| | |

ឯកសារភ្ជាប់ (សូមគូសក្នុងប្រអប់ឯកសារភ្ជាប់មួយ ក្នុងចំណុចនីមួយៗ ខាងក្រោម)៖
១. ☐ សេចក្តីចម្លងសំបុត្រកំណើត ឬបញ្ជាក់កំណើត ☐ ព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ
២. ☐ សៀវភៅស្នាក់នៅថតចម្លង ☐ សៀវភៅគ្រួសារថតចម្លង ☐ លិខិតបញ្ជាក់ទីលំនៅ
៣. ☐ ពាក្យបណ្តឹង (ករណីបាត់បង់) ☐ អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (ករណីខូចខាត)
៤. ☐ សេចក្តីសម្រេច ឬការអនុញ្ញាឱ្យកែតម្រូវទិន្នន័យ (ពីតុលាការ ឬមន្ត្រីអត្រានុកូលដ្ឋាន)

..................ថ្ងៃទី........ខែ..........ឆ្នាំ២០.......
បានឃើញ និងឯកភាព
ហត្ថលេខា និងឈ្មោះមន្ត្រីសម្រេចផ្តល់

..................ថ្ងៃទី........ខែ..........ឆ្នាំ២០.......
បានពិនិត្យ និងបញ្ជាក់ថាព័ត៌មានខាងលើពិតជាត្រឹមត្រូវ
ហត្ថលេខា និងឈ្មោះមន្ត្រីត្រួតពិនិត្យសលាកបត្រ

---

**បង្កាន់ដៃទទួលអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ**

☐ សុំផ្តល់ដំបូង ឬសុំផ្តល់ទុតិយតាករណី ☐ អស់សុពលភាព ☐ បាត់បង់ ☐ ខូចខាត ☐ កែតម្រូវទិន្នន័យ

- ឈ្មោះ ..............................................................................
- កាលបរិច្ឆេទស្នើសុំផ្តល់.................................................................
- កាលបរិច្ឆេទទទួលអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ..............................

01001096876

ឧបសម្ព័ន្ធទី២ នៃប្រកាសលេខ...៤៧២១/ប្រក...ចុះថ្ងៃទី...១១.....ខែ...មេសា....ឆ្នាំ២០២៤
ស្តីពីបែបបទ និងនីតិវិធី នៃការស្នើសុំចុះបញ្ជី ការផ្តល់ ការកែតម្រូវទិន្នន័យ ការលុបបញ្ជី ការធ្វើមោឃភាព
និងការដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ព្រមទាំងបណ្តឹងមិនសុខចិត្ត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យបណ្តឹងករណីបាត់បង់ឬខូចខាត អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ............................... ភេទ...... ខែឆ្នាំកំណើត................. មុខរបរ.......................
ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ........... ផ្លូវ............... ភូមិ................. ឃុំ/សង្កាត់..........................................
ក្រុង/ស្រុក/ខណ្ឌ..................... រាជធានី/ខេត្ត....................... លេខទូរសព្ទ ..................................
ជា ☐ សាមីខ្លួន (ម្ចាស់សំណើ) ឬ ☐ តំណាងឱ្យសាមីខ្លួន ដែលត្រូវជា...............................................

**សូមគោរពជូន**
**ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម**

**កម្មវត្ថុ៖** សំណើសុំប្តឹងអំពី ☐ ការបាត់បង់ ឬ ☐ ការខូចខាត អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដែលមាន លេខ......................................ចុះថ្ងៃទី................................. និងសុំផ្តល់ឡើងវិញ។

សេចក្តីដូចបានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តម អគ្គនាយក** មេត្តាជ្រាបថា អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែររបស់ខ្ញុំបាទ/នាងខ្ញុំ ...........................................................
..............................................................................................................................
..............................................................................................................................

** **ឯកសារភ្ជាប់៖** (១) សាលាកបត្រស្នើសុំផ្តល់ (២) អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (ករណីខូចខាត) (៣) ឯកសារសម្គាល់ (ករណីតំណាងសាមីខ្លួន)។*

អាស្រ័យហេតុនេះ សូម **ឯកឧត្តម អគ្គនាយក** មេត្តាពិនិត្យ និងអនុញ្ញាតផ្តល់នូវអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរខាងលើឡើងវិញដោយសេចក្តីអនុគ្រោះ។

ថ្ងៃ......................... ខែ............. ឆ្នាំ............. ព.ស. ២៥.....
................ ថ្ងៃទី........ ខែ ........... ឆ្នាំ២០......
**ស្នាមមេដៃស្តាំ និងឈ្មោះ**

លេខ....................
បានឃើញ និងសូមគោរពជូន
**លោកប្រធាននាយកដ្ឋាន** មេត្តាពិនិត្យ និងសម្រេច។
រាជធានីភ្នំពេញ ថ្ងៃទី........ ខែ ........... ឆ្នាំ២០......
**ប្រធាន/នាយការិយាល័យជំនាញ**

បានឃើញ និងសូមគោរពជូន
**ឯកឧត្តម អគ្គនាយក** មេត្តាពិនិត្យ និងសម្រេច។
រាជធានីភ្នំពេញ ថ្ងៃទី........ ខែ ........... ឆ្នាំ២០......
**ប្រធាននាយកដ្ឋានរដ្ឋបាលសរុប**

ឧបសម្ព័ន្ធទី៣ នៃប្រកាសលេខ.៤៧៣១ ប្រក....ចុះថ្ងៃទី...១១.....ខែ..កញ្ញា....ឆ្នាំ២០២៤
ស្តីពីបែបបទ និងនីតិវិធី នៃការស្នើសុំចុះបញ្ជី ការផ្តល់ ការកែតម្រូវទិន្នន័យ ការលុបបញ្ជី ការធ្វើមោឃភាព
និងការដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ព្រមទាំងបណ្តឹងមិនសុខចិត្ត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យបណ្តឹងករណីបាត់បង់ឬខូចខាត អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.............................. ភេទ...... ខែឆ្នាំកំណើត................. មុខរបរ.........................
ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ.......... ផ្លូវ............... ភូមិ................. ឃុំ/សង្កាត់..............................................
ក្រុង/ស្រុក/ខណ្ឌ....................... រាជធានី/ខេត្ត...................... លេខទូរសព្ទ ...............................
ជា ☐ សាមីខ្លួន (ម្ចាស់សំណើ) ឬ ☐ តំណាងឱ្យសាមីខ្លួន ដែលត្រូវជា.............................................

**សូមគោរពជូន**
**លោក/លោកស្រីនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ/សង្កាត់**......................

**កម្មវត្ថុ៖** សំណើសុំប្តឹងអំពី ☐ ការបាត់បង់ ឬ ☐ ការខូចខាត អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដែលមាន
លេខ......................................ចុះថ្ងៃទី................................. និងសុំផ្តល់ឡើងវិញ។

សេចក្តីដូចបានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាបជូន **លោក/លោកស្រីនាយប៉ុស្តិ៍** មេត្តាជ្រាបថា អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែររបស់ខ្ញុំបាទ/នាងខ្ញុំ .....................................................
.......................................................................................................................................
.......................................................................................................................................

** **ឯកសារភ្ជាប់៖** (១) សលាកបត្រស្នើសុំផ្តល់ (២) អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (ករណីខូចខាត) (៣) ឯកសារសម្គាល់ (ករណីតំណាងសាមីខ្លួន)។*

អាស្រ័យហេតុនេះ សូម **លោក/លោកស្រីនាយប៉ុស្តិ៍** មេត្តាពិនិត្យ និងអនុញ្ញាតផ្តល់នូវអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរខាងលើឡើងវិញដោយសេចក្តីអនុគ្រោះ។

ថ្ងៃ......................... ខែ............. ឆ្នាំ.............. ព.ស. ២៥.....
............... ថ្ងៃទី........ ខែ ........... ឆ្នាំ២០.....

**ស្នាមមេដៃស្តាំ និងឈ្មោះ**

លេខ...................
បានឃើញ និងសូមគោរពជូន
**លោក/លោកស្រីនាយប៉ុស្តិ៍** មេត្តាពិនិត្យ និងសម្រេច។
....................... ថ្ងៃទី........ ខែ ........... ឆ្នាំ២០......
**មន្ត្រីជំនាញទទួលបន្ទុក**

បានឃើញ និងឯកភាព
..................... ថ្ងៃទី........ ខែ ........... ឆ្នាំ២០......
**នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ/សង្កាត់**...................

ឧបសម្ព័ន្ធទី៤ នៃប្រកាសលេខ ៤៧៣១ ប្រក ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០២៥
ស្តីពីបែបបទ និងនីតិវិធី នៃការស្នើសុំចុះបញ្ជី ការផ្តល់ ការកែតម្រូវទិន្នន័យ ការលុបបញ្ជី ការធ្វើមោឃភាព
និងការដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ព្រមទាំងបណ្តឹងមិនសុខចិត្ត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំកែតម្រូវទិន្នន័យ អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ............................. ភេទ...... ខែឆ្នាំកំណើត................. មុខរបរ .....................
ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ........... ផ្លូវ............... ភូមិ................. ឃុំ/សង្កាត់.................................
ក្រុង/ស្រុក/ខណ្ឌ....................... រាជធានី/ខេត្ត...................... លេខទូរសព្ទ .................................

**សូមគោរពជូន**
**ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម**

**កម្មវត្ថុ៖** សំណើសុំកែតម្រូវទិន្នន័យអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ មានលេខ.......................................
ចុះថ្ងៃទី................................. និងសុំផ្តល់ឡើងវិញ។

សេចក្តីដូចបានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តម អគ្គនាយក** មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំសូមស្នើសុំកែតម្រូវទិន្នន័យអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដូចខាងក្រោម៖

១. កែពី..................................................... ទៅ ...............................................................
២. កែពី..................................................... ទៅ ...............................................................
៣. កែពី..................................................... ទៅ ...............................................................

* **<u>មូលហេតុ៖</u>**.......................................................................................................
..............................................................................................................................
..............................................................................................................................

* ***<u>ឯកសារភ្ជាប់៖</u>*** *(១) សលាកបត្រស្នើសុំផ្តល់ (២) អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរច្បាប់ដើម ឬពាក្យបណ្តឹងករណីបាត់បង់ (៣) សេចក្តីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត ឬព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ (៤) សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ (៥) សេចក្តីសម្រេច ឬការអនុញ្ញាតឱ្យកែតម្រូវទិន្នន័យ (៦) ឯកសារសម្អាងផ្សេងទៀត។*

អាស្រ័យហេតុនេះ សូម **ឯកឧត្តម អគ្គនាយក** មេត្តាអនុញ្ញាតឱ្យកែតម្រូវទិន្នន័យអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែររបស់ខ្ញុំបាទ/នាងខ្ញុំ និងផ្តល់ឡើងវិញដោយសេចក្តីអនុគ្រោះ។

ថ្ងៃ........................ ខែ............. ឆ្នាំ............. ព.ស. ២៥.....

លេខ.................. ................. ថ្ងៃទី........ ខែ ........... ឆ្នាំ២០......

បានពិនិត្យត្រឹមត្រូវ និងសូមគោរពជូន
**លោក/លោកស្រី មេឃុំ/ចៅសង្កាត់ មេត្តាពិនិត្យ និងសម្រេច។**
..................... ថ្ងៃទី........ ខែ ........... ឆ្នាំ២០......
**នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ/សង្កាត់**...................

**ស្នាមមេដៃស្តាំ និងឈ្មោះសាមីខ្លួន**

បានឃើញ និងឯកភាព
..................... ថ្ងៃទី........ ខែ ........... ឆ្នាំ២០......
**មេឃុំ/ចៅសង្កាត់**...................

ឧបសម្ព័ន្ធទី៥ នៃប្រកាសលេខ ៤៧៣១ ប្រក ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០២៥
ស្តីពីបែបបទ និងនីតិវិធី នៃការស្នើសុំចុះបញ្ជី ការផ្តល់ ការកែតម្រូវទិន្នន័យ ការលុបបញ្ជី ការធ្វើមោឃភាព
និងការដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ព្រមទាំងបណ្តឹងមិនសុខចិត្ត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតបដិសេធ

**យោង៖** - ប្រកាសលេខ.............................. ចុះថ្ងៃទី.............. ខែ............. ឆ្នាំ២០២៥ របស់ក្រសួងមហាផ្ទៃ ស្តីពីបែបបទ និងនីតិវិធី នៃការស្នើសុំចុះបញ្ជី ការផ្តល់ ការកែតម្រូវទិន្នន័យ ការលុបបញ្ជី ការធ្វើមោឃភាព និងការដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ព្រមទាំងបណ្តឹងមិនសុខចិត្ត

- សំណើសុំរបស់ឈ្មោះ.......................................... ចុះថ្ងៃទី....... ខែ .......... ឆ្នាំ២០......

**ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ/សង្កាត់ ឬអធិការដ្ឋាននគរបាលក្រុង/ស្រុក/ខណ្ឌ**
**ឬស្នងការដ្ឋាននគរបាលរាជធានី/ខេត្ត ឬនាយកដ្ឋានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ**

...........................................................................

## សូមធ្វើការបដិសេធ

សំណើសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដំបូង ឬទុតិយតា របស់ករណីខាងក្រោម

ឈ្មោះ............................................ អក្សរឡាតាំង............................................ ភេទ...........
ថ្ងៃខែឆ្នាំកំណើត.......................... មុខរបរ.................................................. មានទីលំនៅបច្ចុប្បន្ន
ផ្ទះលេខ........ ផ្លូវ............... ក្រុមទី......... ភូមិ..................... ឃុំ/សង្កាត់..................................
ក្រុង/ស្រុក/ខណ្ឌ...................... រាជធានី/ខេត្ត...................... លេខទូរសព្ទ ...............................
ដែលបានដាក់ពាក្យស្នើសុំកាលពីថ្ងៃទី........ ខែ .......... ឆ្នាំ២០...... ដោយមូលហេតុដូចខាងក្រោម៖
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................

អាស្រ័យហេតុនេះ សូមលោក/លោកស្រីដែលជាម្ចាស់សំណើខាងលើមេត្តាជ្រាប។

ថ្ងៃ......................... ខែ............. ឆ្នាំ............. ព.ស. ២៥.....
............... ថ្ងៃទី....... ខែ .......... ឆ្នាំ២០......

**ហត្ថលេខា និងត្រាអង្គភាព**

ឧបសម្ព័ន្ធទី៦ នៃប្រកាសលេខ...៤៧៧១ ប្រក...ចុះថ្ងៃទី...១១.....ខែ...មេសា...ឆ្នាំ២០២៥
ស្តីពីបែបបទ និងនីតិវិធី នៃការស្នើសុំចុះបញ្ជី ការផ្តល់ ការកែតម្រូវទិន្នន័យ ការលុបបញ្ជី ការធ្វើមោឃភាព និងការដកហូតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ព្រមទាំងបណ្តឹងមិនសុខចិត្ត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្តឹងមិនសុខចិត្ត

**(នឹងការចាត់ចែង ឬការយឺតយ៉ាវ ឬការធ្វេសប្រហែស ឬការសម្រេចនានា របស់មន្ត្រីទទួលបន្ទុកការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ)**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ............................... ភេទ...... ខែឆ្នាំកំណើត................ មុខរបរ .......................
ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ.......... ផ្លូវ............... ភូមិ................. ឃុំ/សង្កាត់..........................................
ក្រុង/ស្រុក/ខណ្ឌ....................... រាជធានី/ខេត្ត...................... លេខទូរសព្ទ ..................................

**សូមគោរពជូន**
**ឯកឧត្តម/លោកជំទាវ/លោក/លោកស្រី**.................................................

**កម្មវត្ថុ៖** សុំប្តឹងមិនសុខចិត្តនឹងការចាត់ចែង ឬការយឺតយ៉ាវ ឬការធ្វេសប្រហែស ឬការសម្រេចនានារបស់មន្ត្រីទទួលបន្ទុកការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។

សេចក្តីដូចបានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តម/លោកជំទាវ/លោក/លោកស្រី**..................................................................... មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំ សូមប្តឹងមិនសុខចិត្តនឹងការចាត់ចែងរបស់មន្ត្រីទទួលការងារអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដូចខាងក្រោម៖

១. ឈ្មោះមន្ត្រីទទួលខុសត្រូវ........................................ តួនាទី.......................................
២. ឈ្មោះអង្គភាព.........................................................................................................
៣. មូលហេតុនៃការប្តឹង....................................................................................................
..........................................................................................................................
..........................................................................................................................

អាស្រ័យហេតុនេះ សូម **ឯកឧត្តម/លោកជំទាវ/លោក/លោកស្រី** មេត្តាពិនិត្យ និងដោះស្រាយបណ្តឹងខាងលើដោយសេចក្តីអនុគ្រោះ។

ថ្ងៃ........................ ខែ............ ឆ្នាំ............. ព.ស. ២៥.....

លេខ...................
បានឃើញ និងសូមគោរពជូន
**ឯកឧត្តម/លោកជំទាវ/លោក/លោកស្រី**
...................................................
មេត្តាពិនិត្យ និងសម្រេច។
.................... ថ្ងៃទី........ ខែ ........... ឆ្នាំ២០.....
**មន្ត្រីទទួលពាក្យបណ្តឹង**

................ ថ្ងៃទី........ ខែ ........... ឆ្នាំ២០......
**ស្នាមមេដៃស្តាំ និងឈ្មោះដើមបណ្តឹង**